# រឿងទី៧៖ព្រះនាងអេសធើរ

**ខគម្ពីរ៖ នាងអេសធើរ៤៖១៦**

«សូមអញ្ជើញទៅប្រមូលជនជាតិយូដាទាំងអស់នៅក្រុងស៊ូសាន ឲ្យតមអាហារសម្រាប់ខ្ញុំ ក្នុងរវាងបីថ្ងៃ គឺទាំងថ្ងៃ ទាំងយប់ មិនត្រូវបរិភោគ ឬផឹកអ្វីឡើយ។ រីឯខ្ញុំ និងស្ត្រីបម្រើរបស់ខ្ញុំ ក៏តមអាហារដែរ។ ខ្ញុំនឹងទៅគាល់ស្តេច ទោះបីខុសច្បាប់ក៏ដោយ បើខ្ញុំត្រូវវិនាស នោះឲ្យវិនាសទៅចុះ»។





ដំណឹងប្រកាសជ្រើសរើសអគ្គមហេសីថ្មីត្រូវបានលេចឮពេញប្រទេស។

ពួកស្រីៗក្រមុំព្រហ្មចារីនាំគ្នាតុបតែងខ្លួនយ៉ាងស្រស់ស្អាតចូលទៅក្នុងវាំង។

នៅក្នុងវាំង មានអ្នកត្រួតត្រាជនជាតិអ៊ីស្រាអែលម្នាក់ឈ្មោះម៉ាដេកាយ លោកមានប្អូនស្រីជីដូនមួយម្នាក់ឈ្មោះ អេសធើរ។

អេសធើរគឺជាក្រមុំព្រហ្មចារីដ៏ស្រស់ស្អាត ត្រូវបានលោកម៉ាដេកាយយកចិញ្ចឹមដូចជាកូនស្រីបង្កើត ក្រោយឪពុកម្តាយនាងបានស្លាប់ទៅ។

អេសធើរក៏បានចូលរួមក្នុងការជ្រើសរើសជាអគ្គមហេសីដែរ។

ស្រីក្រមុំៗដែលបានតុបតែងខ្លួនយ៉ាងស្រស់ស្អាតបានចេញទៅឈរនៅចំពោះស្តេច។ ភ្លាមនោះ ព្រះរាជាបានបើក ភ្នែកធំៗពេលឃើញអេសធើរ។

ក្នុងចំណោមពួកស្រីក្រមុំៗទាំងអស់ ព្រះរាជាសព្វព្រះទ័យអេសធើរជាងគេ។

ដូច្នេះ ព្រះរាជាបានបំពាក់មកុដត្បូងនៅលើក្បាលរបស់អេសធើរ។ ពេលនោះអេសធើរក៏បានក្លាយអគ្គមហេសីថ្មី។

ហើយព្រះរាជា ក៏បានតែងតាំងហាម៉ានឱ្យធ្វើជានាយករដ្ឋមន្ត្រី។ មនុស្សទាំងអស់បានឱនគោរពហាម៉ានជានាយករដ្ឋមន្ត្រីថ្មីនោះ។

ប៉ុន្តែ ខុសតែមនុស្សម្នាក់ដែលឃើញហាម៉ានហើយមិនឱនគោរព នោះគឺម៉ាដេកាយដែលជាអ្នកមើលថែមហាក្សត្រី យានីអេសធើរ។

ម៉ាដេកាយ លោកមិនឱនគោរពអ្នកណាទាំងអស់នៅផែនដីនេះក្រៅពីព្រះជាម្ចាស់តែមួយអង្គគត់។

ហាម៉ានខឹងសម្បារជាខ្លាំង។

ហាម៉ានបានដឹងថា ម៉ាដេកាយគឺជាសាសន៍អ៊ីស្រាអែលដែលថ្វាយបង្គំតែព្រះជាម្ចាស់។

ដូច្នេះ ហាម៉ានបានរៀបគម្រោងមួយ។

ហាម៉ានបានពិភាក្សាជាមួយព្រះរាជាថាអស់អ្នកដែលមិនគោរពតាមច្បាប់របស់ស្តេចនិងត្រូវសម្លាប់ចោលទាំងអស់។

ហាម៉ានបានយករឿងនេះទៅប្រកាសប្រាប់ដល់ប្រជាជនទាំងអស់ដោយប្រើព្រះនាមព្រះរាជា។

«យើងអាចសម្លាប់និងដកហូតយកទ្រព្យសម្បត្តិពីរាស្ត្រអ៊ីស្រាអែលតាមចិត្តបាន»។

រាស្ត្រអ៊ីស្រាអែលមានការភ្ញាក់ផ្អើលជាខ្លាំង ពួកគេនាំគ្នាតមអាហារ ហែកសម្លៀកបំពាក់ ស្រែកយំពេញស្រុក។

ម៉ាដេកាយបានអង្គុយយំនៅមាត់ទ្វាររាជវាំង។

ព្រះនាងអេសធើរបានឮដំណឹងនេះ ទ្រង់មានការភ្ញាក់ផ្អើលជាខ្លាំង។



ព្រះនាងអេសធើរ ទ្រង់មិនហ៊ានចូលទៅគាល់ព្រះរាជាដើម្បីផ្លាស់ប្ដូររាជបញ្ជានេះ បានបញ្ជូនអ្នកបម្រើឱ្យទៅជួប លោកម៉ាដេកាយ។
លោកម៉ាដេកាយក៏រៀបរាប់ប្រាប់ដល់អ្នកបម្រើនោះ។ «ចូរទៅប្រាប់ព្រះនាងថា ដ្បិតការដែលព្រះនាងក្លាយជាមហាក្សត្រីយានីនេះ គឺដើម្បីទុកួលំបាកពេលនេះហើយ»។
អ្នកបម្រើបានយកអ្វីដែលលោកម៉ាដេកាយនិយាយទៅទូលព្រះនាងអេសធើរ។
ព្រះនាងអេសធើរបានឆ្លើយតបទៅលោកម៉ាដេកាយវិញតាមរយៈអ្នកបម្រើស្រីនោះវិញ។
«សូមឱ្យរាស្ត្រអ៊ីស្រាអែលទាំងអស់បានតមអាហារបីថ្ងៃ ហើយអធិស្ឋានសម្រាប់ខ្ញុំផង។
ខ្ញុំក៏នឹងតមអាហារហើយអធិស្ឋានដែរ ទោះត្រូវស្លាប់ក៏ខ្ញុំត្រូវតែចូលទៅគាល់ព្រះរាជា ហើយទូលទ្រង់ដែរ»។
បីថ្ងៃក្រោយ ព្រះនាងអេសធើរក៏បានចូលគាល់ព្រះរាជា។ ព្រះរាជាមានការរីករាយណាស់។
ព្រះរាជាបានមានបន្ទូលថា អ្វីដែលមហាក្សត្រីអេសធើរចង់បាន ទោះត្រូវកាត់ប្រទេសជាពីរក៏ទ្រង់អាចប្រទានឱ្យដែរ។
ព្រះនាងអេសធើរបានរៀបចំពិធីជប់លៀងសម្រាប់ព្រះរាជា ហើយព្រះនាងក៏សុំឱ្យហាម៉ានចូលរួមដែរ។
ពេលទទួលបានការអញ្ជើញឱ្យចូលរួមក្នុងពិធីជប់លៀងនោះភ្លាម ហាម៉ានកាន់តែមានអំណួតខ្លាំងឡើង។
ព្រះរាជា មានអារម្មណ៍ល្អដែលបានចូលរួមក្នុងពិធីជប់លៀងដែលព្រះនាងអេសធើររៀបចំ ទ្រង់ក៏បានសួរពីបំណងប្រថ្នារបស់ព្រះនាង។
ភ្លាមនោះ ព្រះនាងអេសធើរក៏បានឆ្លើយតបដូច្នេះថា៖ «ព្រះករុណា សូមទ្រង់ជួយសង្គ្រោះទូលបង្គំ និងរាស្ត្ររបស់ទូលបង្គំផង»។
ចុងក្រោយហាម៉ានក៏បានស្លាប់ដោយព្យួរកនៅលើសសរ ឈើដ៏ធំ ដែលខ្លួនបានរៀបចំទុកសម្លាប់ម៉ាដេកាយនោះទៅ។
ព្រះរាជា បានដឹងថា កាលពីមុនម៉ាដេកាយធ្លាប់ជួយជីវិតទ្រង់ ដូច្នេះ ទ្រង់ក៏បានលើកម៉ាដេកាយឡើងជានាយករដ្ឋ មន្ត្រីថ្មី។
ព្រះនាងអេសធើរ ក៏បានទូលពីបំណងប្រាថ្នារបស់ទ្រង់ម្ដងទៀតទៅព្រះរាជា។
«សូមទ្រង់លុបពាក្យថាសម្លាប់រាស្ត្រអ៊ីស្រាអែលចោលទៅ»
ព្រះរាជា បានធ្វើតាមអ្វីដែលព្រះនាងអេសធើរចង់បានទាំងអស់។ ដូច្នេះ រាស្ត្រអ៊ីស្រាអែលទាំងអស់ គ្មានអ្នកណាម្នាក់ ត្រូវស្លាប់នោះទេ។
អេសធើរដែលបានក្លាយជាមហាក្សត្រីនេះ បានអធិស្ឋានទៅព្រះជាម្ចាស់ ដើម្បីសុំឱ្យទ្រង់បានជួយសង្គ្រោះដល់រាស្ត្រ អ៊ីស្រាអែលទាំងអស់។

- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (នាងអេសធើរ៤៖១៦)

បើខ្ញុំត្រូវវិនាស នោះឲ្យវិនាសទៅចុះ



**សកម្មភាពទី១** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀនថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



**សកម្មភាពទី២** សូមកាត់រូបរាងត្បូង រួចយកទៅបិទភ្ជាប់ឱ្យត្រូវនឹងរូបរាងដូចគ្នានៅលើមកុដរបស់ព្រះនាងអេសធើរ។ **សម្ភារៈ៖ កាវ, កន្ត្រៃ។**



